វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ទីស្តីការគណៈរដ្ឋមន្ត្រី
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សង្ខេបសម្រាប់
# គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០៦

# ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើភាពក្រីក្រ

តុង គឹមស៊ុន[១]

## សេចក្តីផ្តើម

វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ដែលចាប់ផ្តើមដំបូងឡើងនៅសហរដ្ឋអាមេរិកឆ្នាំ២០០៨ បានរាលដាលយ៉ាងឆាប់រហ័សដល់ប្រទេសជាច្រើននៅជុំវិញពិភពលោក រួមទាំងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា កម្ពុជា ជាដើម។ តាមការព្យាករណ៍ វិបត្តិនេះបណ្តាលឲ្យប្រជាជន ៥៣លាននាក់ថែមទៀត ធ្លាក់ចុះក្រោមបន្ទាត់ភាពក្រីក្រអន្តរជាតិ ១,២៥ដុល្លារ/ថ្ងៃ និង ៦៤លាននាក់ក្រោមបន្ទាត់ភាពក្រីក្រ ២ដុល្លារ/ថ្ងៃ (Chen and Ravallion 2009)។ នៅកម្ពុជា មានការសិក្សាជាច្រើនបានព្យាយាមវាស់វែងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ទៅលើភាពក្រីក្រ (Tong *et al.* 2009; ADB 2008; World Bank 2009) ហើយបានរាយការណ៍ថា ចំនួនប្រជាជនក្រីក្រកើនឡើងគួរឲ្យកត់សំគាល់ ធៀបនឹងពេលមុនកើតវិបត្តិ ប៉ុន្តែលទ្ធផលនេះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីវិធីសាស្ត្រនៃការគណនានោះទេ។ ឧទាហរណ៍ Tong *et al.* (2009) មិនបានគិតចូលនូវ ឥទ្ធិពលនៃការប៉ះទង្គិចផ្សេងៗតាមគ្រួសារ (idiosyncratic shocks) ដែលអាចនាំឲ្យភាពក្រីក្រកើនឡើងដែរ។ ការសិក្សានេះមានគោលដៅត្រួតពិនិត្យពីការប៉ះទង្គិចតាមគ្រួសារ និងកត្តាមិនបានសង្កេតឃើញផ្សេងៗទៀតដែលប៉ះពាល់ដល់ភាពក្រីក្រ ដើម្បីបង្កើន និងពង្រីកចំណេះដឹងឲ្យកាន់តែស៊ីជម្រៅពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើភាពក្រីក្រ។

## វិធីសាស្ត្រ

ការសិក្សាប្រើប្រាស់ទិន្នន័យបានពី អង្កេតបួនជុំជាបន្តបន្ទាប់លើប្រជាជន ៧៩៣គ្រួសារ ក្នុង ៩ភូមិនៅជនបទ ដែលធ្វើឡើងដោយវិទ្យាស្ថាន CDRI នៅឆ្នាំ២០០១, ២០០៤-០៥, ២០០៨ និង ២០១១។ ទាំងការវិភាគបែបពិពណ៌នា (descriptive analysis) និងការវិភាគបែបសេដ្ឋកិច្ចមាត្រសាស្ត្រ (econometric analysis) បានអនុវត្តឡើង ដើម្បីវាស់វែងបម្រែបម្រួលចំនួនជនក្រីក្រក្នុងភូមិជ្រើសរើសទាំង ៩។ ការវិភាគបែបពិពណ៌នាផ្តល់គំនិតជារួមពីការផ្លាស់ប្តូរសុខុមាលភាពគ្រួសារក្នុងគំរូតាង ប៉ុន្តែមិនអាចបំពេញពេញលេញតាមគោលបំណងចម្បង ដើម្បីបង្កើនការយល់ដឹងពីឥទ្ធិពលនៃការប៉ះទង្គិចពីខាងក្រៅទៅលើចំណាយប្រើប្រាស់ និងភាពក្រីក្រពីព្រោះគ្រួសារជាច្រើននៅតំបន់ជនបទក៏តែងទទួលរងនូវការប៉ះទង្គិចតាមគ្រួសារនីមួយៗ ដែលធ្វើឲ្យពួកគាត់ជួបការលំបាកធ្ងន់ធ្ងរដែរ។ ដើម្បីបំពេញបន្ថែមលើការវិភាគបែបពិពណ៌នា ការសិក្សា ក៏បានប្រើម៉ូដែលសេដ្ឋកិច្ចមាត្រសាស្ត្រ (econometric modelling) ដើម្បីកំណត់នូវបម្រែបម្រួលសុខុមាលភាពដ៏ជាក់លាក់បង្កឡើង ដោយការប៉ះទង្គិចពីមជ្ឈដ្ឋានខាងក្រៅផងដែរ។

## លទ្ធផល

នៅឆ្នាំ២០០១ អត្រាភាពក្រីក្រមានជាមធ្យម ៤៣,៩% និងសឹងតែគ្មានការប្រែប្រួលទេនៅឆ្នាំ២០០៤ (៤៣,៨%) មុននឹងធ្លាក់ចុះមកត្រឹម ២៧% នៅឆ្នាំ២០០៨។ នៅឆ្នាំ២០១១ អត្រាភាពក្រីក្រមាន ៤១,២% ឬ ខ្ពស់ជាងឆ្នាំ២០០៨ ដល់ ៥២,៦% និងទាបជាងឆ្នាំ២០០១ ត្រឹមតែ ៦,២% ប៉ុណ្ណោះ។ កំណើនយ៉ាងខ្ពស់នៃអត្រាភាពក្រីក្រពីឆ្នាំ២០០៨ ដល់ ២០១១ ផុសឡើងជាសំខាន់

តារាង១៖ អនុបាតចំនួនជនក្រីក្រនៅឆ្នាំ២០០១-១១ (%)

| | | 2001 | 2004 | 2008 | 2011 |
|---|---|---|---|---|---|
| ភេទ | មេគ្រួសារជាស្ត្រី | 48.0 | 52.2 | 30.2 | 50.1 |
| | មេគ្រួសារជាបុរស | 43.1 | 42.0 | 26.3 | 39.2 |
| មុខរបរ | មេគ្រួសារប្រកបរបរមិនមែនកសិកម្ម | 41.2 | 43.2 | 25.6 | 40.4 |
| | មេគ្រួសារប្រកបរបរកសិកម្ម | 47.1 | 44.8 | 29.4 | 43.1 |
| កម្រិតអប់រំ | មេគ្រួសារមិនបានរៀនសាលា | 52.1 | 55.2 | 30.3 | 41.8 |
| | មេគ្រួសាររៀនកម្រិតបឋមសិក្សា | 44.8 | 45.1 | 30.8 | 45.8 |
| | មេគ្រួសាររៀនកម្រិតមធ្យមសិក្សា ឬខ្ពស់ជាង | 32.0 | 24.6 | 13.8 | 29.8 |
| ភូមិទាំងអស់ | | 43.9 | 43.8 | 27.0 | 41.2 |

ប្រភព៖ ទិន្នន័យអង្កេតគ្រួសាររបស់វិទ្យាស្ថាន CDRI (២០០១-១១)

[១] លោកបណ្ឌិត តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួល កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅវិទ្យាស្ថាន CDRI។

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

រូបភាព១៖ ខ្សែកោងភាពក្រីក្រ




ប្រភព៖ ទិន្នន័យអង្កេតគ្រួសាររបស់វិទ្យាស្ថាន CDRI (២០០១-១១)

ដោយសារការរួមចុះសេដ្ឋកិច្ច និងការប៉ះទង្គិចជាលក្ខណៈបុគ្គល។ ការគួបផ្សំគ្នានៃការប៉ះទង្គិចជារួម (covariate shocks) និងតាមគ្រួសារនីមួយៗ មិនត្រឹមតែរុញច្រានប្រជាជនជនបទមួយចំនួនឲ្យចូលក្នុងភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យប្រជាជនដែលក្រីក្រស្រាប់ កាន់តែចុះក្រថែមទៀត ។

ក្រុមអ្នកស្រាវជ្រាវបានកត់សម្គាល់ថា នៅគ្រប់ឆ្នាំ ចំនួនជនក្រីក្រក្នុងចំណោមគ្រួសារប្រកបរបរកសិកម្ម មានកម្រិតខ្ពស់ជាងគ្រួសារប្រកបរបរក្រៅពីកសិកម្ម។ ស្រដៀងនេះដែរ គ្រួសារមានស្ត្រីជាមេគ្រួសារច្រើនតែក្រីក្រជាង គ្រួសារមានបុរសជាមេគ្រួសារ។ ដូចបានរំពឹងទុក គ្រួសារដែលមានមេគ្រួមិនបានចូលរៀនសាលា ឬរៀនបានត្រឹមកម្រិតបឋមសិក្សា ក្រជាង គ្រួសារដែលមានមេគ្រួ មានការអប់រំកម្រិតមធ្យមសិក្សា ឬខ្ពស់ជាង។

ដើម្បីត្រួតពិនិត្យពីកម្រិតប្រែប្រួលនៃលទ្ធផលសិក្សា ទៅតាមជម្រើសនៃបន្ទាត់ភាពក្រីក្រ ក្រុមស្រាវជ្រាវបានអនុវត្តវិធីសាស្ត្រគណនាអត្រាភាពក្រីក្រ (stochastic dominance approach) ដោយគូសខ្សែកោងភាពក្រីក្រសម្រាប់ឆ្នាំនីមួយៗ។ បើសិនខ្សែកោងភាពក្រីក្រនៃឆ្នាំមួយ ស្ថិតនៅទាំងស្រុង ពីលើខ្សែកោងនៃឆ្នាំមួយទៀត ភាពក្រីក្រនៅឆ្នាំនោះវាមានកម្រិតខ្ពស់ជាង ទោះគេជ្រើសយកបន្ទាត់ភាពក្រីក្រ ឬការវាស់ស្ទង់ភាពក្រីក្របែបណាក្តី។

លទ្ធផលបង្ហាញថា អនុបាតចំនួនជនក្រីក្រក្នុងភូមិជ្រើសរើសទាំង ៩ នៅឆ្នាំ២០១១ បានកើនឡើង ធៀបនឹងឆ្នាំ២០០៨ (រូបភាព១A)។ មានភស្តុតាងបន្ថែមបង្ហាញថា អនុបាតភាពក្រីក្រនៅឆ្នាំ២០១១មានកម្រិតទាបជាងឆ្នាំ២០០៩ (រូបភាព១B)ដែលផ្តល់ជាគំនិតថា កំណើនថ្លៃអាហារនិងប្រេងឥន្ធនៈ និងវិបត្តិហិរញ្ញវត្ថុសាកល បានប៉ះទង្គិចធ្ងន់ធ្ងរដល់សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៩ ហើយបន្ទាប់ពីនោះ សេដ្ឋកិច្ចក៏បានចាប់ផ្តើមងើបឡើងវិញយឺតៗ។ កង្វះទិន្នន័យគ្រួសារនៅឆ្នាំ២០០៩ និង ២០១០ អាចបិទបាំងឥទ្ធិពលនៃវិបត្តិទៅលើ សុខុមាលភាពគ្រួសារនៅតំបន់ជនបទកម្ពុជា។ ម៉្យាងដែលសេដ្ឋកិច្ចមាត្រសាស្ត្រ បានបញ្ជាក់ម្តងទៀតថា បើសិនជាកត្តាផ្សេងទៀតនៅថេរ វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលទំនងជាអាចបង្កើនអនុបាតចំនួនជនក្រីក្រពី ៣៧% ដល់ ៤៤%។ ដោយហេតុថា សេដ្ឋកិច្ចកម្ពុជាបានទទួលរងការប៉ះទង្គិចពីខាងក្រៅធ្ងន់ធ្ងរបំផុត នៅឆ្នាំ២០០៩ ដូច្នេះកំណើនអត្រាភាពក្រីក្រដោយសារវិបត្តិសេដ្ឋកិច្ច វាអាចមានកម្រិតខ្ពស់ជាងនេះទៀត។

## សន្និដ្ឋាន

ការសិក្សានេះបង្ហាញថា ភាពក្រីក្របានកើនឡើងគួរឲ្យកត់សម្គាល់នៅពេលវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បានប៉ះទង្គិចដល់កម្ពុជានៅឆ្នាំ២០០៩។ លទ្ធផលរកឃើញបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើន មានកម្រិតជីវភាពខ្ពស់ជាងបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ហើយងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ ដូចជា ការឡើងថ្លៃអាហារនិងប្រេងឥន្ធនៈ ឬវិបត្តិហិរញ្ញវត្ថុសាកល ជាដើម។ គ្រួសារគ្រប់ប្រភេទទាំងអស់ ទំនងបានទទួលរងឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ច។ ក្រុមស្រាវជ្រាវបានសង្កេតឃើញថា សត្វចិញ្ចឹមបានក្លាយជាកត្តាដ៏សំខាន់ ក្នុងការការពារគ្រួសារពីការធ្លាក់ខ្លួនក្នុងភាពក្រីក្រ ទោះបីចំណែករបស់វាក្នុងចំណូលសរុបបានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំក្តី។ កុមារអាយុពី ៧ ដល់ ១៤ឆ្នាំ ទំនងជាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ច្រើនជាងនៅមុនពេលមានវិបត្តិ។ នេះមានន័យថា យុទ្ធសាស្ត្រទប់ទល់ជាលក្ខណៈក្រៅផ្លូវការ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការការពារគ្រួសារពីការធ្លាក់ខ្លួនក្នុងភាពក្រីក្រ ឬកាន់តែក្រទៅៗ។ ការសិក្សាក៏បានបង្ហាញដែរថា ប្រជាជនកម្ពុជាភាគច្រើនត្រូវការនូវ ប្រព័ន្ធធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាពមួយ។ ទិន្នន័យអង្កេតប្រចាំឆ្នាំទៅលើក្រុមគ្រួសារដដែលៗ ហើយអាចតំណាងឲ្យទូទាំងប្រទេសនោះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីត្រួតពិនិត្យតាមដានភាពក្រីក្រ និងបញ្ហាពាក់ព័ន្ធនានា។